3/4

# ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ភ្នំពេញ

## ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

**************

លេខ: ២៩៩ / ០៨ . ៧ . ២០១១

សាលដីកា

លេខ: ០៤ ក្រ.III.ស/២៩.០២.១២

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

### ក្រុមប្រឹក្សា

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

### ក្រឡាបញ្ជី

កញ្ញា [redacted]

ដើមចោទឈ្មោះ [redacted] ចឹក ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ ទីលំនៅបច្ចុប្បន្ន ភូមិដងរុនកើត ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជា (ដើមបណ្តឹងឧទ្ធរណ៍) ។

មេធាវីតំណាងដោយអាណត្តិ លោក [redacted]

១. ចុងចម្លើយឈ្មោះ [redacted] លន់ ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ មុខរបរៈលក់ដូរ ទីលំនៅបច្ចុប្បន្ន ភូមិអូរស្ងួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជា (ចុងបណ្តឹងឧទ្ធរណ៍) ។

២. ចុងចម្លើយឈ្មោះ [redacted] លួម ភេទស្រី អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើស្រែ ទីលំនៅបច្ចុប្បន្ន ភូមិគោកក្លូច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជា (ចុងបណ្តឹងឧទ្ធរណ៍) ។

៣. ចុងចម្លើយឈ្មោះ [redacted] ធី ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរៈជួសជុលម៉ូតូ ទីលំនៅបច្ចុប្បន្ន ភូមិអូរស្ងួត ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ជា (ចុងបណ្តឹងឧទ្ធរណ៍) ។

កម្មវត្ថុបណ្តឹងទាមទារដោយដើមចោទៈ សុំឲ្យបញ្ជាក់អំពីសិទ្ធិកាន់កាប់ និងសុំឲ្យចុងចម្លើយប្រគល់ដីចំនួន១រ៉ៃ ទំហំ ៤០ម x ៤០ម ស្ថិតនៅភូមិដងរុនលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់ [redacted] វុន និង [redacted] ទី, ខាងកើតទល់នឹងប្រឡាយ, ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និងខាងលិចទល់នឹងឈ្មោះ [redacted] មួយ ។

កម្មវត្ថុបណ្តឹងទាមទារដោយចុងចម្លើយៈ សុំទាមទានូវមរតកដីចំការទំហំ ២៨២០ម² ស្ថិតនៅភូមិដងរុនលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មានព្រំប្រទល់ខាងជើងទល់ [redacted] វុន និង [redacted] ទី, ខាងកើតទល់នឹងប្រឡាយ, ខាងត្បូងទល់នឹងឈ្មោះ [redacted] សួរ និងខាងលិចទល់នឹងឈ្មោះ [redacted] មួយ ពីឈ្មោះ [redacted] ចឹក។



Scanned with CamScanner

37/3

## អង្គហេតុ និង ចំណុចវិវាទ

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចឹក បញ្ជាក់ថា ខ្លួនជាម្ចាស់កម្មសិទ្ធិ បានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៧៩ មកម្លេះ ដោយមានការទទួលស្គាល់ពីអាជ្ញាធរ ភូមិ ឃុំ ស្រុក ហើយខ្លួនបានដាំដំណាំផ្សេងៗនៅលើដីចំនួន១រ៉ៃ ទំហំ ៤០ម×៤០ម ស្ថិតនៅភូមិដងរុនលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ មិនដែលររាក់ខានឡើយ ដែលមានព្រំប្រទល់ខាងជើងទល់ [redacted] វុន និងគ្រូទី, ខាងកើតទល់នឹងប្រឡាយ, ខាងត្បូងទល់នឹងឈ្មោះ [redacted] សូរ និងខាងលិចទល់នឹងឈ្មោះ [redacted] មួយ។ ស្រាប់តែចុងចម្លើយបាននាំគ្នារំលោភបំពានលើដីដែលខ្លួនបានកាន់កាប់ទៀត ហើយចុងចម្លើយទាំងបីនាក់មិនព្រមប្រគល់ដីឲ្យខ្លួនវិញឡើយ។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] លន់ [redacted] លួម និងឈ្មោះ [redacted] ធី បានបញ្ជាក់ថា នៅឆ្នាំ១៩៨៨ ម្តាយពួកខ្លួនឈ្មោះ [redacted] កើន បានទទួលមរណៈភាព ដោយបានបន្សល់នូវដីចំការមួយកន្លែងទំហំ ២៨២០ម² ស្ថិតនៅ ភូមិដងរុនលិច ឃុំបន្ទាយនាង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលមានព្រំប្រទល់ខាងជើងទល់នឹង [redacted] វុន និងគ្រូទី, ខាងកើតទល់នឹងប្រឡាយ, ខាងត្បូងទល់នឹងឈ្មោះ [redacted] សូរ និងខាងលិចទល់នឹងឈ្មោះ [redacted] មួយ, នៅមុនពេលម្តាយរបស់ខ្លួនស្លាប់បានផ្តាំថា «គាត់ជំពាក់លុយគេចំនួនពីរម៉ឺនបាតឲ្យលក់ដីនោះសងបំណុលគេទៅ»។ តែដីនោះពុំបានលក់ទេ ព្រោះឈ្មោះ [redacted] លួម បានទៅស៊ីឈ្នួលគេយកសងម្ចាស់បំណុល។ ដីទំនាស់ គឺជាដីកេរម្តាយខ្លួន ដោយមានលិខិតបញ្ជាក់ពីអាជ្ញាធរដែនដី ពុំមែនជាដីចំការរបស់ [redacted] ចឹក ទេ, ពួកខ្លួនបានឲ្យ [redacted] ចឹក បង្កបង្កើនផលជាបណ្តោះអាសន្នប៉ុណ្ណោះ។

ដើមចោទឈ្មោះ [redacted] ចឹក អះអាងថាៈ ដីទាំងអស់មានទំហំ ៤០ម x ៤០ម ដីនេះមានប្រឡាយ បើរាស់ទាំងប្រឡាយមានទំហំ២៨២ម²។ ខ្លួនរៀបការនៅឆ្នាំ១៩៨០ មានអាយុ២២ឆ្នាំ។ ឆ្នាំ១៩៧៩ ខ្លួនរស់នៅជាមួយម្តាយ ខ្លួនបានកាន់កាប់ដីទាស់នោះ ដីទាស់ជាដីរបស់ខ្លួន មិនមែនជាដីរបស់ម្តាយខ្លួនទេ។ ខ្លួនបានកាន់កាប់ គឺមានប្រជាជនធ្វើសាក្សី តែខ្លួនគ្មានឯកសារបញ្ជាក់ឡើយ។ សំណូមពរ ដូចមេធាវី។

មេធាវីដើមចោទអះអាងថាៈ ពាក់ពន្ធ័នឹងបញ្ហាសមត្ថកិច្ច រឿងនេះមិនទាក់ទងទៅនឹងកិច្ចសន្យាទេ គឺទាក់ទងតែលើការគ្រប់គ្រងដីប៉ុណ្ណោះ ដូចនេះការសម្រេចរបស់តុលាការ ជាការសម្រេចខុសសមត្ថកិច្ច។ ក្នុងរឿងនេះ សាលាដំបូងខេត្តបន្ទាយមានជ័យបានសម្រេចប្រគល់ដីទំហំ ២៨២០ម² ឲ្យចុងចម្លើយជាការសម្រេចខុសឆ្គង ព្រោះកូនក្តីខ្លួនបានអះអាងថា ដីមានទំហំតែ ១៦០០ម² ទេ ហើយការសម្រេចខុសទំហំដីឆ្ងាយណាស់ សូមក្រុមប្រឹក្សាពិចារណា សូមចាត់របៀបទៅលើការកំណត់ទំហំដីរបស់គូភាគីឲ្យបានច្បាស់លាស់សិន និងសុំច្រានចោលសាលក្រមរដ្ឋប្បវេណីលេខ ០៥ «គ» ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ និងសុំបង្វិលសំណុំរឿងនេះទៅគណៈកម្មការដោះស្រាយវិវាទដីធ្លី។

ចុងចម្លើយឈ្មោះ [redacted] លន់ អះអាងថាៈ ដីនេះជារបស់ម្តាយខ្លួន, ដើមចោទគឺជាបងប្រុសខ្លួនបង្កើត បងខ្លួនបានរៀបការនៅឆ្នាំ១៩៨០ ហើយគាត់ទៅរស់នៅខាងប្រពន្ធ។ នៅឆ្នាំ១៩៨៧ ម្តាយខ្លួនឈឺ គឺប្អូនខ្លួន [redacted] លួម និង [redacted] ធី មើលថែទាំ រយៈពេលមួយឆ្នាំម្តាយខ្លួនស្លាប់ មុនស្លាប់គាត់ប្រាប់ថា គាត់ជំពាក់



Scanned with CamScanner

ប្រាក់គេពីរម៉ឺនបាត ឲ្យលក់ដីទំនាស់សងបំណុលគេ មិនបានឲ្យកូនណាម្នាក់ទេ, ប្អូនខ្លួន [redacted] លួម បានទៅស៊ីឈ្នួលគេប្រាំឆ្នាំ ដើម្បីលោះយកដីនោះមកវិញ។ ខ្លួនមិនព្រមប្រគល់ដីនេះទៅឲ្យដើមចោទទេ។ ដីនេះទាំងអស់មានទំហំ ២៨២០ម² តែដើមចោទគាត់ប្តឹងទាមទារ ៤០ម x ៤០ម។ សំណូមពរ សូមតម្កល់សាលក្រមរបស់សាលាដំបូង និងសុំឲ្យដើមចោទបង់ជម្ងឺចិត្តឲ្យខ្លួន។

ចុងចម្លើយឈ្មោះ [redacted] លួម អះអាងថាៈ នៅពេលម្តាយខ្លួនឈឺ បងប្រុសខ្លួន [redacted] ចឹក មិនដែលមកមើលម្តាយទេ ខ្លួនអង្វរគាត់ឲ្យមកមើលម៉ែ តែគាត់មិនមកទេ។ បន្ទាប់ពីម្តាយខ្លួនស្លាប់ ខ្លួនបានទៅស៊ីឈ្នួលគេ ដើម្បីលោះដីនេះមកវិញ។ សំណូមពរ សុំដូចសាលាដំបូង។

ចុងចម្លើយឈ្មោះ [redacted] ធី អះអាងថាៈ ពេលម្តាយខ្លួនឈឺ បងប្រុសខ្លួន [redacted] ចឹក មិនដែលមកមើលម្តាយទេ ខ្លួនអង្វរគាត់ឲ្យមកមើលម៉ែ តែគាត់មិនមកទេ។ សំណូមពរ សុំដូចសាលាដំបូង។

## សំអាងហេតុ

១. បណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចឹក ជាដើមចោទ ធ្វើនៅក្នុងកំណត់ច្បាប់ តាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី,

២. គូភាគីជាបងប្អូនបង្កើតនឹងគ្នា ប៉ុន្តែដើមចោទបានមានប្រពន្ធ តាំងពីឆ្នាំ១៩៨០ ហើយក៏ចុះទៅរស់នៅជាមួយប្រពន្ធរហូតមក តាមការអះអាងរបស់ចុងចម្លើយថា នៅពេលម្តាយមានជម្ងឺ រហូតដល់ស្លាប់នៅឆ្នាំ១៩៨៨ ក៏ដើមចោទពុំបានមកជួយមើលថែម្តាយដែរ ក្រោយពីម្តាយស្លាប់ឈ្មោះនេះក៏មកទាមទារយកដីទំហំ ៤០ម គុណ ៤០ម (មួយរ៉ៃ) ពីពួកខ្លួន, ចុងចម្លើយបានបញ្ជាក់បន្ថែមថា មុននឹងស្លាប់ម្តាយខ្លួនបានប្រាប់ពួកខ្លួនឲ្យទៅលោះយកដីនោះពីម្ចាស់បំណុល ព្រោះគាត់បានបញ្ចាំគេ ហើយពួកខ្លួនទាំង៣នាក់ក៏នាំគ្នាខំប្រឹងរកប្រាក់ដោយស៊ីឈ្នួលធ្វើការឲ្យគេ បានប្រាក់ក៏នាំគ្នាយកទៅសុំលោះដីនេះមកកាន់កាប់វិញ, ដីនេះនៅក្នុងដីទំហំ២.៨២០ម² ដែលខ្លួនដាក់បណ្តឹងតប សុំកាន់កាប់ទាំងមូល, ឯដើមចោទបានយកដីមួយចំនួនរួចហើយ ។

៣. សំអាងហេតុ និងសេចក្តីសម្រេច នៃសាលក្រមរដ្ឋប្បវេណីលេខ ០៥ «គ» ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ មានភាពច្បាស់លាស់ និងត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

## ហេតុនេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ០៩ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចឹក ជាដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែច្រានចោលដោយផ្ទុយនឹងគតិច្បាប់,

២. តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០៥ «គ» ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល ។

៣. ប្រាក់ប្រដាប់ក្តីដាក់បន្ទុកលើដើមចោទ ។



Scanned with CamScanner

សាលដីកានេះ ទាញហេតុផលផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ បើកផ្លូវសាទុក្ខ០១ខែ គិតចាប់ពីថ្ងៃបាន–ទទួលសាលដីកានេះ ។

ក្រឡាបញ្ជី　　　　ចៅក្រមប្រឹក្សា　　　　ប្រធានក្រុមប្រឹក្សា

ហត្ថលេខា: [redacted]

.......................................................................................................................

បានឃើញ
ប្រធានក្រុមប្រឹក្សា
[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១២
ក្រឡាបញ្ជី
[redacted]



Scanned with CamScanner